

ឧបសៅ សង្ហា

# លទ្ធិប្រជាធិបតេយ្យសេរី និង ការអប់រំ



ពិនិត្យឡើងវិញអំពីព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្រ្តខ្មែរ

## មាតិការឿង

អារម្ភកថា ........ 2
លទ្ធិប្រជាធិបតេយ្យសេរី ជាអ្វី ? ........ 3
ការអប់រំផ្តាច់ការ និង សេរី ........ 7
ការអប់រំ នៅសម័យអាណាព្យាបាល ........ 13
សេចក្តីសន្និដ្ឋាន ........ 21

# អារម្ភកថា

តាំងតែពីឆ្នាំ១៩៩០មកម្លេះ គេតែងនាំគ្នានិយាយថា ទុក្ខនៅស្រុកខ្មែរ គឺកើតមានឡើង ដោយសារអ្នកដឹកនាំខ្មែរ បានយកមកអនុវត្តលទ្ធិប្រជាធិតេយ្យ របស់មហាប្រទេសសេរី ដោយឥតបានធ្វើ ការអប់រំជាមុន ដល់ប្រជាពលរដ្ឋខ្លួន អំពីគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ។ គេនិយាយទៀតថា ដោយសារប្រជាពលរដ្ឋខ្មែរ មានទម្លាប់ ដូចប្រជាពលរដ្ឋដ៏ទៃទៀត នៅក្នុងដំបន់អាស៊ី រស់ក្រោមទម្ងន់ របបរាជាធិបតេយ្យ អស់ច្រើនសតវត្សមកហើយ បានជាមាន ការលំបាកច្រើន ដើម្បីយល់លំនាំ ក្នុងការអនុវត្តលទ្ធិប្រជាធិតេយ្យ។

យើងសួរជាសំណួរជាច្រើនថា : តើលទ្ធិប្រជាធិតេយ្យ ជាចំណេះវិទ្យាសាស្ត្រ ត្រូវចាំបាច់រៀនវាឲចេះសិន មុននឹងយកវាមកអនុវត្ត ? ហេតុអ្វីក៏គេនាំគ្នា ដាក់កំហុស ជានិច្ចដល់រាស្ត្រ នៅពេលណា មានបញ្ហា ក្នុងការប្រព្រឹត្តលទ្ធិប្រជាធិបតេយ្យ ក្នុងប្រទេសមួយ ? តើមហាប្រទេសសេរី ត្រូវគេយកមកធ្វើ ជាគំរូដាច់ខាត នៃរបៀបអនុវត្តលទ្ធិប្រជាធិបតេយ្យ ?

# លទ្ធិប្រជាធិបតេយ្យសេរី ជាអ្វី ?

ហេតុអ្វីបានជាប្រជាពលរដ្ឋខ្មែរ ដែលជាប្រជាពលរដ្ឋមួយ តាមស្នាមប្រវត្តិសាស្ត្រ ជាអ្នកចេះដឹងច្បាស់ថា អ្វីជាអំពើអាក្រក់ អ្វីជាអំពើល្អ អនុលោមតាមព្រះពុទ្ធសាសនា ធ្លាប់ស្គាល់ ភាពរុងរឿងរបស់ជាតិខ្លួន ក៏ដូចជា ការអាម៉ាស់មុខដែរ ទៅជាមានការលំបាកយល់ អំពីការប្រព្រឹត្ត នៃលទ្ធិប្រជាធិបតេយ្យទៅវិញ ? តើលទ្ធិប្រជាធិបតេយ្យ ជាគំនិតដាច់មុខ នៃប្រជាពលរដ្ឋ របស់បស្ចិមប្រទេស ? តើលទ្ធិនេះ មាននៅក្នុងការវិវឌ្ឍន៍ជាធម្មជាតិ នៃសភាពចម្រើន របស់មនុស្សជាតិ ? តើប្រជាពលរដ្ឋខ្មែរ ធ្លាប់បានឃើញស្នាមលទ្ធិនេះ ក្នុងប្រវត្តិសាស្ត្រ ប្រទេសខ្លួនដែរឬទេ ?

លទ្ធិប្រជាធិបតេយ្យ ជាលទ្ធិមួយ ស្រួលយល់បំផុត សំរាប់មនុស្សគ្រប់រូប ព្រោះលទ្ធិប្រជាធិបេតយ្យ មានគោលសំខាន់តែមួយគឺ ការស្រឡាញ់សមភាព : « មនុស្សម្នាក់ៗ មានចំណង់ដូចគ្នា គឺចង់មាន សុភមង្គល, អត្ថប្រយោជន៍, ស្គាល់សេចក្ដីរីករាយ, មានសេចក្ដីសង្ឃឹមក្នុងជីវិត »។ ចំណង់នេះ ជាចំណង់ជាធម្មជាតិ របស់មនុស្សគ្រប់រូបនៅក្នុងសង្គម។ តែចំណង់ ជាឯកត្តភូតទាំងឡាយនេះ ក្នុងលទ្ធិប្រជាធិបតេយ្យ គឺជាចំណង់ សំរាប់បំរើប្រយោជន៍ដល់ប្រជាជាតិខ្លួន ដែលមានក្នុង គំនិត នៃតិនីតិជន

គ្រប់រូប ដែលទុកមាតុភូមិជា វិជាតមាតា (មាតាបង្កើត) ជាអ្នកមានគុណ ត្រូវសងបំណុលដ៏ធំមហិមា មិនអាចអស់បានក្នុងជីវិតខ្លួន។

តែយើងដឹងថា ក្នុងសង្គមសេរីនិមួយៗ តែងតែមាន អ្នកក្រ និង អ្នកមាន រស់នៅជាមួយគ្នា ដូច្នេះត្រូវមានច្បាប់មួយ ដើម្បីការពារសមភាពក្នុងសង្គម។ បើប្រសិនអ្នកតែងច្បាប់ ធ្វើច្បាប់ណា តម្រូវឲអ្នកក្រ តាមស្វែងរក មធ្យោបាយ ចេញពីភាពក្រីក្រជាអសារ (ចេញមិនរួច) និង ធ្វើឲអ្នកមាន អត់ទ្រាំពុំបាន, ច្បាប់នោះ ប្រកដជាវាពុំអាចគង់វង់បាននោះឡើយ ព្រោះច្បាប់នោះ មិនមែនជាច្បាប់ សំរាប់ការពារប្រជាពលរដ្ឋនោះទេ។ ច្បាប់ល្អ ក្នុងលទ្ធិប្រជាធិបេតយ្យសេរី គឺគ្រប់ច្បាប់ណា ដែលការពារអ្នកក្រ ឲអាចមានលទ្ធភាព កាត់ចោលបាន នូវសេចក្តីទុក្ខលំបាក ដែលវាកើតមានពី សេចក្តីក្រីក្រ របស់ខ្លួន និង ឲអ្នកមាន មានសិទ្ធសេរីភាព ស្វែងរកទ្រព្យ ជាធម្មតាបាន, តែទប់ស្កាត់មិនឲអ្នកមានទ្រព្យនោះ រំលោភលើអ្នកក្រ និង ច្បាប់រដ្ឋបាន។ បើនិយាយឲស្រួលយល់ គឺច្បាប់កំរិត នូវការរស់នៅអ្នកគ្មានទ្រព្យ ឲមានជីវភាពថ្លៃថ្នូរ ជាប្រជាពលរដ្ឋ ដែលយើងឲឈ្មោះថា « សុភមង្គលជាអប្បបរិមា ក្នុងជីវភាពរស់នៅ » និង កំរិតទ្រព្យសម្បត្តិអ្នកមានទ្រព្យ កុំឲល្មោភខ្លាំងនឹងទ្រព្យសម្បត្តិ ឲវាក្លាយទៅជា សេចក្តីក្តៅក្រហាយ របស់ប្រជាពលរដ្ឋ ព្រោះថា

វិសមភាពសំខាន់ក្នុងសង្គម គឺសេចក្ដីល្មោភខ្លាំងនឹងទ្រព្យ ដែលនាំឲខូចកិត្តិយ ដល់ជាតិ និង ជាទុក្ខវេទនារបស់ប្រជាពលរដ្ឋ។ ដូចយ៉ាងនៅស្រុកខ្មែរបច្ចុប្បន្ននេះ អស់លោកអ្នកកាន់អំណាច គាត់មានទ្រព្យ លើគំនរទុក្ខរាស្ត្រ គឺគាត់នាំគ្នាប្រព្រឹត្ត អំពើពុករលួយចំក្ដី មិនចំក្ដី ដែលនាំ ឲរាស្ត្រក្ដៅក្រហាយ។ ពួកគាត់យកអំណាច រដ្ឋធ្វើជា របរ រកទ្រព្យ ដូចយ៉ាង បើគាត់ ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិ គាត់ប្រកបរបរ បើកសាលាឯកជន, បើជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម គឺគាត់ធ្វើ ជាអ្នកជំនួញខាងអាហរណកម្ម និង និហារីយកម្ម បើជារដ្ឋមន្ត្រីក្រសួងបរិស្ថាន គឺគាត់ច្បាស់ ជាមានមុខរបរ រកស៊ីខាងព្រៃឈើ។ ភូមិគ្រិះ និង ឡានជាន់ទំនើប របស់ពួកគាត់ គឺជាទ្រព្យ នាំឲជាតិគ្មានសេចក្ដីថ្លៃថ្នូរ និង រាស្ត្រគ្មានកិត្តិយស។ របរ របស់បុគ្គលណាមួយ ធ្វើនៅពេលដែលខ្លួន កំពុងកាន់អំណាចរដ្ឋផងដែរ គេទុក ភាពប្រព្រឹត្តស្របគ្នានេះជា « ទំនាស់ នៃប្រយោជន៍ » (Conflit d’intérêts) ដែលជាទោសមួយដ៏សំខាន់ ចំពោះអ្នកប្រព្រឹត្ត នៅក្នុងប្រទេសគោរពលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

នៅទីនេះ យើងសង្ខេបបានថា លទ្ធិប្រជាធិបតេយ្យ មិនមែនគ្រាន់ជា គំនិតសមភាពនោះឡើយ គឺវាជាអំពើដែលត្រូវតែធ្វើ ឲមានដាច់ខាត នូវសមភាពក្នុងសង្គមដែលមាន ច្បាប់សំរាប់ការពារ ប្រយោជន៍បុគ្គលម្នាក់ៗ

ផង, ការពារ ប្រយោជន៍រួមផង។ ក្នុងចំណុច សមភាពនេះ ឯង ដែលយើង ត្រូវយកមកធ្វើ ជាគោលសំខាន់បំផុត ក្នុងលទ្ធិប្រជាធិបតេយ្យសេរី។ តែសមភាពនេះ ខុសពី សមភាព ក្នុងរបបកុម្មុយនិស្ត និង អំណាចផ្តាច់ការ ដែល ជា សមភាព គ្មានសេរីភាព បញ្ចេញមតិ និង សេរីភាព នយោបាយ ដែលជាគោលការណ៍ សំខាន់មួយទៀត នៃ លទ្ធិប្រជាធិបតេយ្យសេរី។ យើងដឹងថា ក្នុងរបបរាជា និយមសក្តិភូមិ, របបផ្តាច់ការនិយម ក៏ដូចរបបកុម្មុយ និស្តដែរ គេធ្វើច្បាប់ ដើម្បីបំរើ ប្រយោជន៍អំណាចអ្នក ដឹកនាំ។ ច្បាប់ទាំងឡាយនោះ ជាច្បាប់សំរាប់ធ្វើ ឲប្រជា ពលរដ្ឋរខ្លាច និង គោរពដាច់ខាតអំណាចរបស់គេ ដែល គេទុកខ្លួនគេជាម្ចាស់ នៃអំណាចនោះ។ សមភាពគ្មាន សេរីភាព ក្នុងរបបផ្តាច់ការ ជាអាការៈក្រៅ បញ្ឆោត ដូច យ៉ាង របបបច្ចុប្បន្ននៅកម្ពុជា គេយកទំនៀមទម្លាប់ ជាតិ មកធ្វើមធ្យោបាយ បោកបញ្ឆោតរាស្ត្រ ដើម្បីការពារ ប្រយោជន៍គេ ដូច្នេះ គេជ្រើសរើស តែទំនៀមទម្លាប់ណា ដែល រលួយមកប្រើ ដើម្បី បំផ្លាញជាតិ និង ទុកប្រជា ពលរដ្ឋ ឲរស់ក្នុងភាពល្ងង់ខ្លៅ ព្រោះភាពល្ងង់ខ្លៅ នៃរាស្ត្រ នេះ វាជា ការធានាការពារអំណាចគេ។ ក្នុងចំណុចនេះ អ្នកមើលឃើញស្រុកខ្មែរ តែនឹងភ្នែកគឺ ជាជនគ្មានគតិ អាចស៊ិកសំដីថា នៅស្រុកខ្មែរ មានមហាវិទ្យាល័យខ្នាត អន្តរជាតិដ៏ច្រើន ចុះហេតុអ្វី បានជាយើង យល់ឃើញថា

អ្នកកាន់អំណាចបច្ចុប្បន្ន មានបំណង ឲរាស្ត្ររស់នៅក្នុង សេចក្ដីល្ងង់ខ្លៅ ?

## ការអប់រំផ្ដាច់ការ និង សេរី

ការអប់រំ ក្នុងលទ្ធិប្រជាធិបតេយ្យសេរី និង នៅក្នុងរបប ផ្ដាច់ការ :

ក្នុងមតិនេះហើយ ដែលយើងចង់លើកមកពិចារណាដែរ អំពីការអប់រំ មាននៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី និង មាននៅក្នុងរបបផ្ដាច់ការ។ យើងដឹងថា របៀបអប់រំមាន ច្រើនយ៉ាង :

អប់រំឲខ្លាច, អប់រំឲនៅតែល្ងង់, អប់រំឲគ្រាន់តែចេះតាម គ្រូថា, អប់រំបង្កើតប្រាជ្ញា និង អប់រំជាតិ។ ការអប់រំទាំង៥ យ៉ាងនេះ សុទ្ធតែមាន គោលដៅវាច្បាស់លាស់ ហើយសំរាប់ បំរើប្រយោជន៍អ្វីមួយ ដែលអ្នកអប់រំចង់បាន។ យើងគួរ ដឹងដែរថា ការចេះដឹងក្នុងចំណេះណាមួយ ទោះបីចំណេះ នោះ មានលក្ខណៈ ជាវិទ្យាសាស្ត្រវិជ្ជាក៏ដោយ ក៏មិន ប្រាកដ ជានាំបង្កើតប្រាជ្ញា ដល់អ្នកចេះដឹងនោះឡើយ ព្រោះថា ចំណេះ ជាមេរៀន មានក្បួនរួចស្រេច តម្រូវឲអ្នក រៀន មានសតិចំណាំដើម្បីរៀនឲចាំ នូវអ្វី ដែលអ្នក បង្រៀន គាត់ដាក់ឲរៀន។ បើអ្នករៀនណា មានសតិ ចំណាំច្រើន គេអាចនឹងចាំបានច្រើន ក្នុងមេរៀននោះ ដើម្បីនឹង សូត្រមកវិញឲដូចវិជ្ជា ដែលខ្លួនបានរៀន, តែ

មិនពិត ជាអ្នកចេះនោះ មានប្រាជ្ញា ឬ នាំបង្កើតប្រាជ្ញាអ្វី នោះឡើយ ពីព្រោះ ប្រាជ្ញា ជាផ្លែផ្កា នៃការសិក្សាពិចារណាដ៏មានជម្រៅមួយ លើវិជ្ជាណាមួយ ដែលខុសពី ការរៀនសូត្រ ដែលដាក់ឲរៀនចេះ ចំណាំដោយយកសតិចំណាំ ជាឃ្លាំង ទុកចំណេះ។ ប្រាជ្ញា ជាសម្ថភាព នៃការបង្កើតការ ពិចារណា ក្នុងគុណធម៌ សំរាប់ការចំរើន នៃមនុស្សជាតិ ឯចំណែកការចេះ ជាសតិចំណាំ នៃចំណេះ ដែលមាននៅ ក្នុងសង្គមជាតិ។ អ្នកចេះមុខវិជ្ជាណាមួយ អាចនៅជា មនុស្សល្ងង់ គ្មានប្រាជ្ញា, តែអ្នកមានប្រាជ្ញា ក្នុងគុណធម៌ ពុំអាចជាមនុស្សល្ងង់បាននោះឡើយ។ តែប្រាជ្ញា ដែល គ្មានគុណធម៌ ជាភាពល្ងង់ខ្លៅ ជាទីបំផុត អាចទុកវា ជាសត្រូវ ចំពោះមនុស្សជាតិទៀតក៏បានដែរ។

មុននឹងចូលក្នុងអន្តរវត្ត នៃការអប់រំ យើងសូមនាំអ្នក អាន ត្រឡប់ទៅមើលវិស័យនេះ ជាសង្ខេប ក្នុងអតីត កាលជាតិខ្មែរបន្តិចសិន ដើម្បីងាយស្រួលនឹង តាមដាន អំពីការវិវឌ្ឍន៏ នៃវិស័យនេះ ក្នុងសង្គមខ្មែរ។ ដូចយើង ធ្លាប់បានសរសេររួចមកហើយថា ធាតុសង្គមខ្មែរ ក្នុង អតីតកាល ជាសង្គមសក្តិភូមិ ដែលមាន ការអប់រំឲខ្លាច ផង ឲនៅតែល្ងង់ខ្លៅផង និង ឲចេះសូត្រតាមគ្រូថាផង។ មុមទាំងបីនេះ ជាគ្រឹះ នៃរបបរាជានិយមសក្តិភូមិ ដែល គេធ្វើ សំរាប់តែ រក្សារបបគេ ឲមានជីវិត ជាអនន្ត។

ការអប់រំឲខ្លាច គឺឲរអារាងចាលនឹងធ្វើអ្វី ប្រឆាំងនឹងអ្នកដឹកនាំ ដូចយ៉ាង គេអប់រំរាស្ត្រ ឲខ្លាចស្តេច ទុកស្តេចជាមនុស្សប្រសិទ្ធិ ស្មើនឹងអទិទេព ឥតអាចរិះគន់បាននោះឡើយ។ ការបិទសិទ្ធិសេរីភាព ឲចេះគិតពិចារណា អំពីសកម្មភាព របស់អ្នកដឹកនាំនេះឯង ជាការអប់រំ ឲរាស្ត្ររស់ក្នុងភាពល្ងង់ខ្លៅជានិច្ច មើលឃើញតែភាពល្អ ដែលអ្នកដឹកនាំគេធ្វើ សំរាប់តែរកប្រយោជន៏គេតែប៉ុណ្ណោះ ដូចយ៉ាង ការកែឆ្នៃហេតុការណ៏ មិនពិត ឲទៅជាប្រវត្តិសាស្ត្រជាតិ សំរាប់បំរើប្រយោជន៏នយោបាយរបស់គេ។ ដើម្បីរកអ្វី ដែលគេចង់បាន គេនាំគ្នាបង្កើត ការអប់រំរាស្ត្រ ឲចេះតែសូត្រតាមតែគេ តម្រូវឲចេះសូត្រតែប៉ុណ្ណោះ ដូចយ៉ាង គេតែងដំបូន្មានទាំងឡាយឲគោរព ដើម្បីកាត់មនុស្ស ឲរស់នៅក្នុងហ្វូងមនុស្ស ដែលគេផ្សាំងបាន សំរាប់ប្រើប្រាស់ ដូចបសុសត្វនោះឯង។ របបរាជានិយមសក្តិភូមិ តែងតែ យកទំនៀមទម្លាប់អំណាច របស់គេ ទុកជាទំនៀមទម្លាប់ នៃប្រជារាស្ត្រផង ទុកជាប្រពៃណីជាតិផង ដូច្នេះគេយក ការអប់រំទាំងបីយ៉ាងនេះ ជាពុម្ព សំរាប់អំរំប្រជារាស្ត្រ ឲក្លាយ ជាប្រជារាស្ត្រ ងាយដឹកនាំ ដើម្បីស្រួលរកប្រយោជន៏គេ គឺអំណាចផ្តាច់ការ។ យើងគួរដឹងដែរថា ទំនៀមទម្លាប់ ជាចំណេះ កើតមានឡើង ពីការធ្វើឡើងវិញ នូវអ្វីមួយជាច្រើនដង រហូតការធ្វើនោះ ក្លាយជាទម្លាប់ដែរត្រូវធ្វើ ហើយទម្លាប់ មានអស់រយៈពេលដ៏យូរ

អង្វែង ក៏ក្លាយទៅជាទំនៀមទម្លាប់ របស់មនុស្សមួយក្រុម រស់នៅក្នុងសង្គមមួយ ឬនៅត្រង់ទីកន្លែងណាមួយ។

ដូច្នេះទំនៀមទម្លាប់មិនមែន ជាចរន្ត នៃភាពទំនើប។ វាឋិតនៅក្នុងដៃមនុស្ស ស្រករក្រោយៗមក ដែលកំពុងរស់នៅក្នុងសង្គមថ្មី ដែលវាតម្រូវឲ្យខ្លួន រស់តាមលំនាំថ្មី ដែលវាអាចមានភាពផ្ទុយ ពីទំនៀមទម្លាប់ ដែលខ្លួនធ្លាប់បានស្គាល់។ ភាពផ្ទុយនេះហើយដែល របបរាជានិយមសក្តិភូមិ គេទុកវាជា សត្រូវរបស់គេ ហើយដើម្បី រក្សាទំនៀមទម្លាប់ ទោះបីវាលែងប្រើបានក៏ដោយ តែវាជាសេចក្តីសុខរបស់គេ ដូច្នេះ គេនៅតែរក្សា ការអប់រំទាំងបីយ៉ាង ដែលយើង បានរៀបរាប់ ខាងលើ ដែលជាដំបូន្មាន ឲចេះកោតខ្លាចអំណាចគេតែប៉ុណ្ណោះ។

តើនៅក្នុងស្រុកខ្មែរគ្រប់សម័យ ធ្លាប់មាន ការអប់រំជាតិដែរឬទេ ?

ក្នុងរបបរាជានិយមសក្តិភូមិ ក៏ដូច របបសង្គមរាស្ត្រនិយម (១៩៥៦-១៩៧០) ក៏ដូចរបបខ្មែរក្រហម (១៩៧៥-១៩៧៨) ក៏ដូច របបនៅក្រោមអាណាព្យាបាលយៀកណាម (១៩៧៩-១៩៨៩) ការអប់រំជាតិ គ្មានមាននោះឡើយ ព្រោះថា ការអប់រំជាតិ ជាការអប់រំប្រជាពលរដ្ឋ ឲស្គាល់សិទ្ធិនិង កតព្វកិច្ច របស់ខ្លួនចំពោះជាតិ ដូច្នេះការអប់រំជាតិមិនមែនជាការ ឲដំបូន្មាន ឲខ្លាចនោះឡើយ តែផ្ទុយទៅ

វិញ ជាការអប់រំ ឲមានសេចក្ដីក្លាហាន ក្នុងការបញ្ចេញមតិ និង ហ៊ានចូលរួមយ៉ាងសកម្ម ក្នុងគ្រប់សកម្មភាពសង្គម ដែលអាចនាំឲជាតិ មានការចម្រើន តាមកន្លងគុណធម៌ គ្រប់វិស័យជាតិ។ ទោះបីមាន ការបង្កើតសាលារៀនច្រើន គ្រប់លំដាប់សិក្សាយ៉ាងណាក៏ដោយ តែការអប់រំនោះ មិនមែនជា ការអប់រំជាតិ ព្រោះថា ការអប់រំជាតិ ជាការអប់រំ នាំឲប្រជារាស្ត្រ មានប្រាជ្ញា ដើម្បីឲបុគ្គលម្នាក់ៗ ក្លាយជាការី របស់ជាតិ ទទួលការខុសត្រូវចំពោះខ្លួនឯងផ្ទាល់ផង និង វាសនាជាតិផង ដូច្នេះសាលារៀន ដែលមានច្រើននោះ គឺគ្រាន់ជាអាគារ ឥតព្រលឹងជាតិនោះឯង។ ការអប់រំ ដែលនាំបង្កើតប្រាជ្ញា លុះត្រាតែការអប់រំនោះ ឋិតនៅក្នុងសង្គមមួយ ដែលឲតម្លៃទៅលើសេរីភាព សមភាព នៃសមាជិកខ្លួន។ ការអប់រំទោះបី មានកំរិតបច្ចេកទេសខ្ពង់ខ្ពស់ យ៉ាងណាក៏ដោយតែវា ឋិតនៅក្នុងសង្គម ពុករលួយ ក្នុងប្រទេស ដឹងនាំដោយ អំណាចផ្ដាច់ការ ពិតជាពុំមែន ជារស្មី សំរាប់ជាតិនោះឡើយ ព្រោះអ្នកចេះ ចេះត្រឹមតែសូត្រតាម និង បំរើប្រយោជន៏អ្នកដឹងនាំតែប៉ុណ្ណោះ ដូចយ៉ាង ការអប់រំនៅក្នុងរបបកុម្មុយនិស្ត អប់រំប្រជាពលរដ្ឋ ឲបំរើតែមនោគមវិជ្ជា នៃគណបក្សដឹកនាំ ឲរាស្ត្ររស់ ជាទាសៈទាសី ដាច់ថ្លៃរបស់បក្សកុម្មុយនិស្តតែប៉ុណ្ណោះ ដូចយ៉ាងនៅប្រទេសកូរ៉េខាងជើង ធ្វើកាំជ្រួញបាញ់បានចម្ងាយឆ្ងាយ សំរាប់តែ

បង្ហាញ នូវកិត្យានុភាព នៃរបបដឹកនាំ ប៉ុន្តែរបបនេះ បង្កើត នូវទុរ្ភិក្សក្នុងសង្គម នាំឲរាស្ត្រ រស់ក្នុងទុក្ខវេទនា ជាទីបំផុត។ ម្យ៉ាងទៀតដែរ ដូចនៅ ប្រទេសចិនកុម្មុយនិស្ត គេបង្កើតដំបន់សេដ្ឋកិច្ចពិសេស សំរាប់ធ្វើជាទូកញ្ចក់ តាំងទំនិញប្រណិតភាព របស់មស្សិមប្រទេស សំរាប់បំភាន់ភ្នែកប្រជាពលរដ្ឋខ្លួនថា ក្រោមការដឹកនាំគណបក្សកុម្មុយនិស្ត ប្រទេសចិន មានការចម្រើនជឿនលឿនអស្ចារ្យ តែការចម្រើននេះ ជានយោបាយបិទបាំង នូវទុក្ខវេទនា នៃជនជាតិចិន ចំនួនយ៉ាងតិច ៩០% នៃប្រជាពលរដ្ឋ។ ដូចប្រទេសយៀកណាម គេឲជនជាតិគេរាប់លាននាក់ មករស់នៅក្នុងស្រុកខ្មែរ ដើម្បីដោះស្រាយបញ្ហាទុរ្ភិក្ស និង ការអត់ការងារ នៅក្នុងស្រុកខ្លួន ដែលជាបញ្ហាអាចបង្កើត ការបះបោរប្រឆាំងនឹងបក្សកុម្មុនិស្តយៀកណាម ដែលជា គណបក្សកាន់អំណាច។ ដូច្នេះយៀកណាម គេយកទឹកដីកម្ពុជា ជាការដោះស្រាយ នូវបញ្ហាសង្គមផង និង នយោបាយគេផង។ រួមសេចក្ដីទៅ ការអប់រំ ក្នុងរបបកុម្មុយនិស្ត ក៏ដូចនៅក្នុងរបបផ្ដាច់ការ ជាការអប់រំ គ្មានការបង្កើត នូវប្រាជ្ញា ដល់ប្រជាពលរដ្ឋនោះឡើយ តែផ្ទុយទៅវិញ គឺជាការអប់រំ ឲប្រជាពលរដ្ឋខ្លាចផង នៅល្ងង់ជានិច្ចផង និងចេះតែស្ដាប់តាម តែអ្នកដឹកនាំ គេបង្គាប់ឲស្ដាប់តាមតែប៉ុណ្ណោះ។

# ការអប់រំ នៅសម័យអាណាព្យាបាល

គួរដឹងដែរអំពី ការអប់រំនៅស្រុកខ្មែរ ក្នុងរបបអាណាព្យាបាលបារាំង (១៨៦៣-១៩៥៣) : ពិតណាស់ហើយថា បារាំង គេនាំវិទ្យាសាស្ត្រវិជ្ជា ចូលមកក្នុងស្រុកខ្មែរ ដើម្បីបង្រៀន យុវជនខ្មែរ ឲបានចេះដឹង អំពីមុខវិជ្ជានេះ តែបារាំង ឥតបានកែទម្រង់សង្គម និង របបដឹកនាំខ្មែរ ដែលមាន លក្ខណៈសក្តិភូមិ ដើម្បីឲប្រទេសខ្មែរ ក្លាយជាប្រទេសសម័យនោះឡើយ ដូច្នេះ ការអប់រំថ្មី ដែលបារាំងយកមកធ្វើនៅក្នុងសង្គមចាស់ គឺគ្រាន់តែ មានបំណងយកវិស័យអប់រំខ្មែរ មកធ្វើកម្មសិទ្ធិ របស់បារាំង ដើម្បី បំរើ ប្រយោជន៍ អំណាចអាណានិគមបារាំងតែប៉ុណ្ណោះ។ ដូច្នេះ ការអប់រំថ្មីនេះ គ្មានបានជួយបង្កើតប្រាជ្ញាអ្វីនោះឡើយ ដល់ប្រជាពលរដ្ឋខ្មែរ មិនតែប៉ុណ្ណោះ បារាំងថែមទាំងយកភាសា របស់ខ្លួនយកមកធ្វើជាយាន សំរាប់អប់រំយុវជនខ្មែរ ក្នុងមធ្យោបាយ សំរាប់កំទេចប្រលឹងជាតិខ្មែរ ដែលមាន នៅក្នុងភាសាជាតិ។ ក្នុងចំណុចនេះ យើងដកស្រង់ សក្ខីកម្ម របស់លោក ប៊ុណ្ណ ចន្ទម៉ុល ដែលលោកបានសរសេរទុក ក្នុងសៀវភៅមួយ មានចំណងជើងថា « គុកនយោបាយ » មានសេចក្តីដូចខាងក្រោមនេះ :

*« ការតស៊ូ ចាប់ផ្ដើមដំបូង តាមផ្លូវសារពត៌មាន...គ្រានោះទើបមាន វីរជន ដឹកនាំបបួលគ្នីគ្នា ឲធ្វើការតស៊ូប្រឆាំង*

នឹងបារាំង យកឥស្សរភាព ពីវាមកវិញ ក្នុងពេលដែល បារាំង កំពុងមានអំណាចនៅឡើយ គឺថា ចង្គូម ឬ ធ្លុងវា នៅពេញមាត់ ស្រួចលែមនៅឡើយ វាចង់ធ្វើអ្វីយើងក៏ បានតាមចិត្តវា ឥតអ្វីទប់បានឡើយ។ ការតស៊ូនេះ ចាប់ ផ្ដើមដំបូង ក្នុងឆ្នាំ១៩៣៦ តាមផ្លូវ សារពត៌មានមួយ ឈ្មោះថា « សារព័ត៌មាន នគរវត្ត »។ សារព័ត៌មាននេះ បានពន្យល់ ណែនាំ ដាស់ស្មារតីបងប្អូនខ្មែរយើង ដែល ដេកលក់ ដែលរងកម្មវេទនា ដែលបាក់ស្បាតធ្លាប់ខ្លាច បារាំង ដាក់គុក ឬ សម្លាប់ ឲ្យភ្ញាក់ស្មារតីឡើង ឲ្យចេះស្នេហា ជាតិ ឲ្យចេះតស៊ូ ឥតខ្លាចស្លាប់ ដើម្បីយក ឥស្សរភាព ពី បារាំងមកវិញ ដែលវា បានដណ្ដើមពីយើង ជិត១០០ឆ្នាំ ហើយ។ « កាសែត នគរវត្ត » ចាប់ចេញដំបូង តែពីរដង ទេ ក្នុងមួយអាទិត្យ...។ លោក ប៉ាច ឈឺន កាន់កាប់មុខ ងារជា ចាងហ្វាងកាសែត ត្បិតលោក ជាវីរជនម្នាក់ ស្នេហាជាតិមុតមាំ ក្នុងបណ្ដា ក្រុមបដិវត្តទាំងអស់។ ឯលោក ស៉ឺ ហុង បានតម្រូវ ឲ្យធ្វើជា គណនេយ្យករ ត្បិត លោក ក៏ជាមនុស្សត្រង់ ហើយជា អ្នកស្នេហាជាតិដែរ។ ចំណែកអ្នកនិពន្ធមាន លោក ស៊ឹង ង៉ុកថាញ់ លោកប៉ាច ឈឺន លោក ស៊ឹម វ៉ារ លោក ពិទូរ កៈសេម និង លោក ជុំ មួ ង។ ក្រោយទើបមាន លោក មហា ញ៉ុក ថែម និង លោក មហា សា មន ចូលជួយទៀត។ កាលកាសែត នគរវត្ត ចេញដំបូង អ្នកដែលអាន ភាគច្រើនមាន តែអ្នកក្រីក្រ

*និង កម្មករ ដែលពុំសូវចេះ ភាសាបារាំង អានកាសែត ភាសាបារាំង មិនបាន។ ឯអស់លោក និង ថីថុង គេមិនយកក្អែកបៀតទេ ដោយគេមើលងាយ ស្អប់ខ្ពើមអក្សរជាតិ។ ពិសេសគឺ អស់លោកជាន់នោះ អានអក្សខ្មែរ ពុំបានផង ត្បិតមិនខំរៀនអក្សរជាតិទេ, គេខំរៀនអក្សរបារាំង ត្បិតអក្សរបារាំង មានតម្លៃខ្លាំងណាស់ជាន់នោះ ឯអក្សរខ្មែរ ចុះទាប ដល់ថ្នាក់ក្រោមសូន្យ។ មើលតែកាសែតបារាំងឈ្មោះ ឡាវេរីតេ (La Vérité), អូពីនីញ៉ុង (Opinion), អាំប៉ាស្យាល់ (Impartial) និង « Presse de Saigon » ជាដើម។ បើចង់មើលការសែតខ្មែរ ដោយឮល្បីថាល្អមើល គេបត់ដាក់ពីក្នុងកាសែតបារាំង កុំឲគេមើលឃើញ ខ្លាចថាអន់ ឬ មិនចេះបារាំង...។ « ជាន់នោះ អ្នកណា មិនចេះអក្សរបារាំង ចេះតែអក្សខ្មែរ ឥតបានការអ្វីធ្វើនឹងគេទេ ត្បិតគេ ប្រើតែអក្សរបារាំង, ទោះខាងរាជការក្តី ខាងជំនួញក្តី ដូចគ្នា។ អ្នកនិយាយបារាំង ហ៊ឺហាណាស់ ដូចទេវតា ចុះពីស្ថានសួគ៌។ ធ្វើពាក្យបណ្តឹង ឬ សុំអ្វីៗ ត្រូវតែធ្វើជាបារាំង ទោះខាងរាជការខ្មែរក្តី ខាងរាជការបារាំងក្តី ប្រើតែអក្សរបារាំងដូចគ្នា។ បើមិនចេះ ត្រូវពឹងគេធ្វើឲ ទើបបានការ។ មិនមែនតែ អក្សរបារាំងទេ ដែលថ្លៃថ្នូរ សូម្បីតែស្រីបារាំង ក៏ប្រុសខ្មែរយើង ជាន់ជាយកន្ទេលវាមិនបានដែរ។ និស្សិតខ្មែរ ដែលបានសញ្ញាប័ត្រខ្ពស់ពីស្រុកបារាំង លុះត្រឡប់មកវិញ ដោយទាំងប្រពន្ធបារាំងមក*

ផង ដល់សុំធ្វើការ ក្នុងរាជការ គេមិនឲ គេប្រាប់ថា ទាល់តែលែងប្រពន្ធបារាំងទៅ ទើបឲធ្វើការ។ បុរសនោះ បង្ខំលែងប្រពន្ធបារាំងទៅ ទើបបារាំង គេឲធ្វើការ ជាមន្ត្រីខាងរាជការខ្មែរ។ ឯនាងបារាំងនោះ ត្រូវគេ បញ្ជូនត្រឡប់ ទៅស្រុកបារាំងវិញទៅ។ រឿងនេះមានច្រើនគ្នា តែសូម មិនបញ្ចេញឈ្មោះ។ ឯយួនដែលជា ខ្ញុំបារាំងដូចខ្មែរដែរ ប៉ុន្តែវាមានឥទ្ធិពល ជាងខ្មែរ វាក្អេងក្អាងដាក់ខ្មែរគ្រប់កន្លែងរាជការ និង ជំនួញ ត្បិតវាចេះផ្គាប់ផ្គុនបារាំងឲស្រឡាញ់វា ស្តាប់វា ធ្វើបាបខ្មែរ។ ចំណែកឯចិនវិញ ក៏វាឡើងចាង លើខ្មែរណាស់ដែរ ត្បិតពួកគេ ច្រើនតែអ្នកមានសម្បត្តិ គេតាំងខ្លួនគេខ្ពស់នៅស្រុកខ្មែរ ប្រហែលនឹងបារាំងដែរ។ កុំថាដល់ទៅស្រីល្អជា សូម្បីតែ ស្រីផ្កាមាសចិន ក៏ខ្មែរយើង ពុំអាចគប់ភ័នវាបានឡើយ បើបានស្គាល់ចិនជិតដិតហើយ វានាំទៅ ព្រោចស្រីពេស្យាចិនជាមួយវាទើបបានខ្លះ។ ខ្មែរជាន់នោះ អន់ជាងយួនចិនទៅទៀត។ សម័យនោះ ដោយអក្សរបារាំង វប្បធម៌បារាំងផ្សាយឥទ្ធិពល មកលើអក្សរសាស្ត្រខ្មែរ លើវប្បធម៌ខ្មែរខ្លាំងណាស់ទៅ អក្សរសាស្ត្រយើង វប្បធម៌យើង ក៏រត់ទៅពួនសម្ងំ នៅក្នុងវត្តអារាមអស់។ បើកុំតែបាន គុណព្រះសង្ឃខ្មែរ ដែលជាអ្នក ទ្រទ្រង់ថែរក្សាទុក ឲបានគង់វង្សដល់សព្វថ្ងៃ កុំអីអក្សរសាស្ត្រខ្មែរ រលាយបាត់សូន្យឈឹងពីប្រទេសកម្ពុជាទៅហើយ។ ចាប់ពីឆ្នាំ១៩៤២ មក បារាំង

លែងអោយ សរសេរពាក្យខ្មែរ ជាផ្លូវការហើយ គេបង្កើតអក្សរ រ៉ូម៉ានីហ្សេ (Romanisé) ឬ ក៏ហៅថា « កុកងឺខ្មែរ » គឺ សរសេរពាក្យខ្មែរ ជាអក្សរបារាំងវិញ តាំងពីរាជការជាន់ខ្ពស់ រហូតដល់ឃុំ។ ការសែត ក៏ចេញជាអក្សរ រ៉ូម៉ានីហ្សេដែរ។ ហេតុអ្វី ? មកពីបារាំងគេធ្វើឲជាតិគេ ងាយរៀនភាសាខ្មែរ ដោយសរសេរជា រ៉ូម៉ានីហ្សេ ត្បិតជាន់នោះបារាំង គេកំពុងតែដាក់គ្នាគេ មកនៅស្រុកអាណានិគមឲច្រើន ហើយគេចង់ បញ្ចូលចំណុះគេ ធ្វើជាស្រុកបារាំងផង ហៅថាប្រទេសបារាំង ឯនាយសមុទ្រ (La France d’outre-Mer) គឺគេចង់ សង្កត់យើង កុំឲរើខ្លួនរួច ឲក្លាយជាតិ ទៅជាបារាំងឲអស់ទៅ ទោះចេះបារាំងក៏ដោយ មិនចេះក៏ដោយ ដូចនៅ ប៉ុងឌីស៊ីរីចណ្ឌេនាំគរ ជាខេត្ត នៃប្រទេសណា,ដែលក្លឹង ក្លាយសញ្ជាតិ ជាបារាំងខ្មៅអស់។ ឯខ្មែរយើងជាន់នោះ និង មុននោះ មានសុំចូកជាតិបារាំងខ្លះដែរ ដោយគេយល់ឃើញថា ជាតិឯងថោកទាបណាស់ ហើយបានទាំងផ្លាស់ឈ្មោះ ទាំងត្រកូល ទៅជាបារាំងអស់ គេសប្បាយចិត្ត នឹងដូរជាតិខ្មែរទាបថោក ទៅជាជាតិបារាំងខ្ពង់ខ្ពស់ថ្លៃថ្លាទៅវិញ។ ក៏ប៉ុន្តែ សូមជ្រាបថា នៅជំនាន់នោះ ខ្មែរនៅខិតខំតស៊ូ ប្រើភាសាខ្មែរ នៅបានច្រើននៅឡើយ។ ដូចជា ក្រសួងមហាផ្ទៃ, យុត្តិធម៌ សិក្សាធិការជាតិ ក្រុមព្រះតម្រួត ។ល។ ជាដើម។ ដល់ពេល

*ទាមទារបានសេរីភាព ឯករាជ្យ ពីបារាំងបានខ្លះនោះ ត្រឡប់ ជាប្រើអក្សរបារាំងនៅវិញ។*

*...ចំណែកជាតិយួន គេដើរទាន់សម័យ គេដេញបារាំងចេញ គេប្រើភាសារជាតិគេជាផ្លូវការ គេឲកុមារា កុមារីរៀន ភាសាអង់គ្លេស។ ពេលជប៉ុនចូលស្រុក គេឲកូនចៅគេ រៀនភាសាជប៉ុន។ ឥឡូវនេះ នៅសកលលោកទាំងមូលប្រទេសដែលទើបបានឯករាជ្យថ្មីៗ គេតែងតែ ប្រើភាសាជាតិគេ ស្ទើរតែគ្រប់ប្រទេសទៅហើយ ចម្លែកអី តែជនជាតិខ្មែរយើង នៅក្រាញដល់ណាទៀត ? សព្វថ្ងៃ សីលធម៌ វប្បធម៌ ទំនៀមទម្លាប់ខ្មែរ ចង់រលំរលាយទៅចង់អស់ពីស្រុកទៅហើយ ! ហេតុនេះគួរបងប្អូនរួមឈាម មេត្តាជួយគិត ឲបានវែងឆ្ងាយរឿង អក្សរជាតិយើងផង។*

*តុលាការសឹក :*

*...គេយកទៅដាក់ ក្នុងបន្ទប់តូចល្មមមួយ មួយទទឹងប្រហែល៣ម៉ែត បណ្តោយប្រហែល៦ម៉ែត។ នៅនោះខ្ញុំឃើញអ្នកទោសជាតិយួន៧នាក់ នៅនោះដែរ។ ពួកយួនសួរខ្ញុំ ជាភាសាយួនថា គេដាក់ទោសប៉ុន្មានឆ្នាំ? ខ្ញុំឆ្លើយថាណាំណាំ (៥ឆ្នាំ) ពួកនោះនាំគ្នាសើចគិលឡើងថា បិឌីកូងណូងវ៉ូយ ! ខ្ញុំមិនចេះពាក្យ « កូងណូង » នេះសោះ មិនដឹងថា យ៉ាងម៉េច គិតមិនយល់ន័យសោះ ខ្ញុំថាមិនយល់ទេ ខ្ញុំគិតទៅឃើញថា ក្រែងគេ បញ្ជូនទៅពេជ្រនិល ត្បិត*

នៅស្រុកខ្មែរ មានកន្លែងពេជ្រនិលនេះមួយទេ ជាកន្លែងចាញ់ សម្រាប់ឃុំមនុស្សទោសឧក្រិដ្ឋ។ គិតចុះគិតឡើងនៅតែមិនយល់ដដែល។ មិត្តខ្ញុំពីនាក់ទៀតសួរថា : គេសើចរឿងអី ? គេបញ្ជូនពួកយើងទៅណា ? គ្រានោះមានខ្មែរក្រោមម្នាក់ ក្នុងចំណោមយួនទាំង៧នាក់នោះ ដែលខ្ញុំស្មានថាជាយួនទាំងអស់គ្នា ខ្មែរនោះអត់មិនបាន ក៏ឆ្លើយប្រាប់ថា កូងណូងនោះ គឺកោះត្រឡាច ! ឮពាក្យថាកោះត្រឡាចភ្លាម ខ្ញុំក៏ភ្ញាក់ខ្លួន ដូចគេកន្ត្រាក់តែម្តងត្រចៀកហឹងអស់ ស្តាប់អ្វីលែងឮ ហើយដោយនឹកឃើញថាអញម្តងហ្នឹង អស់សង្ឃឹមថា នឹងរស់រានមានជីវិតត្រឡប់មកស្រុកវិញហើយ ត្បិតធ្លាប់ឮគេដំណាលតៗមកថា កោះត្រឡាចនោះ នៅកណ្តាលសមុទ្រឆ្ងាយណាស់ ជាកន្លែងដាក់មនុស្សទោសឧក្រិដ្ឋ។ ក្រោយនោះ ខ្ញុំក៏ក្រោកទៅអង្គុយជិតខ្មែរក្រោមនោះ ហើយសួរ ពីស្ថានភាពកោះត្រឡាចយ៉ាងម៉េចខ្លះ។ គាត់នោះ បានអធិប្បាយ សព្វគ្រប់ប្រាប់ខ្ញុំ ហើយគាត់ ប្រាប់ថា គាត់ឯង គេដាក់ទោសប្រាំឆ្នាំ មិនយូរប៉ុន្មានទេ...

បងប្អូនជួយពិចារណាមើល ជាតិខ្មែរដូចគ្នា មិនព្រមទទួលស្គាល់ខ្មែរគ្នាឯង មិនព្រម និយាយភាសាខ្មែរ ប៉ុន្តែដោយអង្គុយស្តាប់ទៅប្រហែល ជាតឹងទ្រូងណាស់មើលទៅបានជាគេ ព្រមនិយាយខ្មែរមករកខ្ញុំ។ គ្រានោះខ្ញុំសួរទៅវិញថា បងឯងខ្មែរ ម៉េចមិនព្រមនិយាយខ្មែរ ណែនាំពួក

*ខ្ញុំផង ព្រោះពួកខ្ញុំមិនចេះយួនទេ ! គេឆ្លើយថា និយាយខ្មែរទៅពួកយួន មើលងាយអញ ថា អញជាជាតិខ្មែរ។ សូមបងប្អូន ជួយស្ដាប់មើលចុះ ជាតិខ្មែរយើង ឲតែចេះភាសាបរទេសហើយ និយាយតែភាសាគេ លែងនិយាយភាសាខ្លួនឯងសោះ ថាជាតិឯង ជាជាតិថោកទាបទៅវិញ។ ដូចយ៉ាងជាតិខ្មែរយើង ដែលចេះភាសាបារាំងសែស ខ្លះជាវរជនផង គេនាំកូនចៅគ្រួសារគេ និយាយតែបារាំង រហូតដល់ភ្លេចភាសាជាតិចោលអស់ ថាជាភាសាថោកទាបទៅវិញ។ មើលចុះស្រីយួន ដែលយកប្ដីបារាំង ដល់មានកូន គេបង្ហាត់ ឲនិយាយតែពាក្យយួន ឲស្រឡាញ់ជាតិយួនខាងម្ដាយជាងឪពុក។ បើជាស្ត្រីខ្មែរយើងវិញ បើបានប្ដីបារាំងហើយ កូនប្រុសកូនស្រី និយាយ តែបារាំង ឥតចេះខ្មែរសោះ អប់រំស្រឡាញ់ជាតិឪពុកជាងជាតិម្ដាយ។ បើនិយាយខ្មែរទៅខ្លាចគេថា មិនមែនកូនបារាំង។ នេះជា គំនិតខ្ញុំគេ តពូជត្រកូល ឥតភ្ញាក់រលឹកសោះ។ បើមានជាតិខ្មែរណា ភ្ញាក់រលឹក ជួយណែនាំ តាមផ្លូវនយោបាយ ដើម្បីឲប្រទេសជាតិ រួចពីទាសភាព មានសេរីភាពឡើងវិញ អ្នកនោះ គេសម្គាល់ថា ជាមនុស្សថោកទាបអាវ៉ាសែ ឥតខ្លឹមសារ គេឥតហ៊ានដើរជិតទេ ខ្លាចមានរឿង ដល់ខ្លួនគេទៀត... »*

យោងតាមសក្ខីកម្ម របស់លោក ប៉ុណ្ណ ចន្ទម៉ុល យើងយល់ឃើញថា ការអប់រំ នៅជំនាន់បារាំងត្រួតខ្មែរ វាគ្មានជា

រស្មីអ្វីទេ សំរាប់ជាតិខ្មែរនោះឡើយ វាមានតែជួយបន្ទាប វប្បធម៌ជាតិ ភាសាជាតិ ដែលជាហេតុ នាំអ្នកចេះដឹងខ្មែរ នាំគ្នាយល់ឃើញថា វប្បធម៌ជាតិ ជាវប្បធម៌ធ្វើអោយ (បង្កើតក្នុងស្រុក) វាគ្មានតម្លៃល្អ ដូចវប្បធម៌ មកពី បរទេសនោះទេ តែអ្នកចេះដឹងខ្មែរ ភ្លេចគិតថា ទោះបី គាត់ ឲតម្លៃ ទៅលើវប្បធម៌បរទេស ខំធ្វើឫក ជាបរទេស និយាយភាសាបរទេស ជាមួយខ្មែរគ្នាឯង តែជនបរទេស គេទុកគាត់ជា អ្នកចេះក្រោមគេ ព្រោះគេ ទុកខ្លួនគេ ជា គ្រូ របស់គាត់ជានិច្ច។ ការយកវប្បធម៌បរទេស ជាខ្នាតនៃ ការចេះដឹងនេះឯង វាជា រនាំងបាំង អ្នកចេះដឹងនិង ប្រជារាស្ត្រ ចែកជាពិភពពីរដាច់គ្នា មួយជា ពិភពអ្នក ចេះ តែគ្មានប្រាជ្ញា មួយទៀត ជាពិភពអ្នកល្ងង់ ឥតភ័ព្វ វាសនា។ ពិភពទាំងពីរនេះហើយ ជាសង្គមខ្មែរសព្វថ្ងៃនេះ រស់នៅក្នុង ឥទ្ធិពលបរទេសផង និង នៅក្នុងភាពល្ងង់ ខ្លៅផង ដែលជា កត្តានាំឲជាតិ គ្មានប្រាជ្ញា គឺថា គ្មាន ព្រលឹងជាតិ។

## សេចក្តីសន្និដ្ឋាន

លទ្ធិប្រជាធិបតេយ្យសេរី ជាលទ្ធិមួយ តម្រូវឲមាន ប្រាជ្ញា ជាតិ ដែលជា គ្រឹះរបស់សង្គម សំរាប់ទ្រទ្រង់សេរីភាពប្រជា ពលរដ្ឋ។ សេរីភាព ជាកត្តា ធ្វើឲបានប្រសើរ នៃ ជោគវាសនា របស់ប្រជាពលរដ្ឋ ហើយនៅពេលណា សេរី

ភាពនេះ មានជំនួយ ពីអ្នកចេះដឹង គ្រប់វិស័យ បច្ចេកទេស ជំនួបនេះ ជាទស្សនវិស័យ គ្មានទីបំផុត សំរាប់សកម្មភាព របស់មនុស្ស ក្នុងការស្វែងរក ការជឿនលឿន នៃសង្គម។ ក្នុងសង្គមខ្មែរ រហូតមកដល់បច្ចុប្បន្នកាល ជំនួបនេះ វាគ្មានមាននៅឡើយ ព្រោះ ខ្មែរជាជន អត់ធ្មត់នឹង អកុសលគ្រប់បែបយ៉ាង តាមការញញិម នៅបបូរមាត់ តែមាត់ញញិមនោះ លាក់ នូវទុក្ខពិពិធ មានការតាន់តឹងក្នុងចិត្ត ស្ទើរទ្រាំពុំបាន។ នេះ ជាអារម្មណ៍ នៃមនុស្ស រងកាត់បញ្ហា ឬ ជា មនុស្ស ទាល់ច្រកក្នុង ជីវិតរស់នៅ ឬ មកពី ភាពកំសត់នោះ វាមានភាពហួសហេតុពេក។ តែគេ សង្កេតឃើញថា ជនខ្មែរ គាត់យំ រហ័យណាស់ នៅពេលជួបប្រទះព្រឹត្តិការណ៍ទុក្ខសោក ហើយការសូរយំ អណ្ដឹតអណ្ដន់នេះ ជួនកាល មានរយៈពេលយូរអង្វែង តែទឹកភ្នែកនេះ ជួនកាល មិនមែនជា ការយំ ពីទុក្ខនោះឡើយ តែជា សញ្ញា នៃការទទួលយកទុក្ខនោះ ជាកម្មផល របស់ខ្លួន នៅក្នុងគំនិត នៃចាគប័ត្រ[11]។ ចាគប័ត្រនេះ ក៏វាមាននៅក្នុងគំនិត នៃអ្នកចេះដឹងខ្មែរ នៅចំពោះមុខអំណាច នៃអ្នកដឹកនាំ ព្រោះខ្លួន ទទួលការអប់រំនៅក្នុងផ្នត់គំនិត មិនទុកចំណោះទាំងឡាយ មាន

11 ចាគប័ត្រ, ការអត់ធ្មត់ទ្រាំទ្រ, résignation។

មកពី ការពិចារណា ជានិច្ចភាព ដោយអាស្រ័យខ្លួនឯង តែជាចំណេះ របស់គ្រូដាច់ខាត ត្រូវទុកជាទិដ្ឋិ (dogme)។

ប្រជាករ បែបនេះ ជាអ្នកបង្កើត និង រក្សា របបផ្តាច់ការ ព្រោះគ្មាន ការតស៊ូសង្គម និង នយោបាយ ដើម្បី សេរីភាព និង គ្មានការពិចារណា រកផ្លូវត្រូវ និង ផ្លូវប្រាកដនិយម។ នត្ថិភាព ទាំងឡាយនេះហើយ ដែលជា ឧបសគ្គ សំរាប់ បណ្តុះ លទ្ធិប្រជាធិបតេយ្យសេរី នៅក្នុងស្រុកខ្មែរ ទោះបីលទ្ធិនេះ ត្រូវបានអង្គការសហប្រជាជាតិ យកមកធ្វើជា ដំណោះស្រាយ នៃខេមរវិបត្តិនយោបាយ នៅឆ្នាំ ១៩៩១ នៅក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព រវាង យុទ្ធការីខ្មែរ។ ជាការពិតហើយថា គណបក្សកាន់អំណាចសព្វថ្ងៃ ជាអ្នកផ្តើន កិច្ចព្រមព្រៀងសន្តិភាព បានងាយស្រួល ព្រោះតែ គណបក្សប្រឆាំង គ្មានយុទ្ធសាស្ត្រប្រឆាំងច្បាស់លាស់ និង ប្រជាពលរដ្ឋខ្មែរ គ្មានសេចក្តីទុកចិត្ត លើខ្លួនឯង ថាខ្លួនជាម្ចាស់ នៃអំណាច គឺថាជាអធិបតី ដែលជាកត្តា នៃជ័យជំនះ លើរបបផ្តាច់ការ ហើយនាំគ្នាបន្ត រស់នៅក្រោម ការអប់រំ ឱ្យស្គាល់តែសេចក្តីខ្លាច ហើយ ខ្លបខ្លាចនៅក្នុងសេចក្តីទុក្ខ របស់ខ្លួនគ្មានទីបញ្ចប់។

ពាក្យកាព្យ មួយឃ្លា ដកស្រង់ពី ប្រតិទិនឆ្នាំ ២០១៩ របស់ វត្តពោធិវង្ស ដែលបង្ហាញ នូវស្ថានភាពពិតនៅស្រុកខ្មែរ មានសេចក្តីថា :

« **ស្រុកខ្មែរឥឡូវខ្វះអ្នកប្រាជ្ញពិត ទោះច្រើនបណ្ឌិត និង អ្នកមានយស សម្បូរមន្រ្តី ដែលមានតែឈ្មោះ នាំជាតិធ្លាក់ជ្រោះ ព្រោះតែតណ្ហា។** »